១២៨

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

104/7

តុលាការកំពូល

# សាធារណរដ្ឋខ្មែរ

## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២១៥

ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២

សាលដីកា

លេខ: ១៦២

ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣

ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោមៈ

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោកស្រី [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី

លោក [redacted]

តំណាងមហាអយ្យការ

លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៨៣ "ក្រVបស" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ២១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ របស់តុលាការកំពូល។

ពិបទ: មនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលចែងឲ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

-ជនជាប់ចោទ

១-ឈ្មោះ [redacted] "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបររកស៊ីលក់ដូរ កើតនៅភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ មានទីលំនៅបច្ចុប្បន្នភូមិចុងខ្លុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]" ប្រពន្ធឈ្មោះ[redacted]មានកូន០១នាក់ ទោសពីមុនគ្មាន។



Scanned by CamScanner

104
6

២-ឈ្មោះ [redacted] ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៤ឆ្នាំ ជាតិខ្មែរឥស្លាម កើតនៅភូមិត្រពាំងខ្ពង់ ឃុំឈូកស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ចាម មុខរបរធ្វើស្រែ ទីលំនៅបច្ចុប្បន្ន នៅភូមិចុងខ្ពុយ ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ឪពុកឈ្មោះ [redacted] ម" ម្តាយឈ្មោះ [redacted] បពន្ធឈ្មោះ [redacted] មានកូន៧នាក់ ទោសពីមុនគ្មាន។

-ជនជាប់ចោទទាំងពីរមានមេធាវីលោក [redacted]

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិក្រាំងតាសែន សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។

-កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ ជនរងគ្រោះឈ្មោះ [redacted] បានធ្វើដំណើរមកពីលេងផ្ទះកូននៅភូមិចុងខ្ពុង ឃុំអូរសណ្តាន់ ស្រុកក្រគរ ខេត្តពោធិសាត់ ដោយជិះម៉ូតូលើកំណាត់ផ្លូវជាតិលេខ៥ ឆ្ពោះមកទីរួមខេត្តពោធិសាត់។ លុះមកដល់ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិ៍សាត់ នៅវេលាម៉ោង១១ និង៣០នាទី មានជនល្មើសចំនួន០២នាក់ ជិះម៉ូតូឌុបគ្នាមកតាមក្រោយដល់កៀកបានបាញ់ជនរងគ្រោះនឹងកាំភ្លើងខ្លី១គ្រាប់ ត្រូវក្រោមឆ្អឹងជំនីខាងឆ្វេងបណ្តាលឱ្យរបួសធ្ងន់ និងបណ្តាលអោយស្លាប់ក្រោយពីបានសង្គ្រោះនៅមន្ទីរពេទ្យ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ថា:

ចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ពីបទមនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅ ភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ០៤"ផ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលបានសម្រេចៈ

១-អោយឈ្មោះ [redacted] ចខ្លួនពីបទចោទ ពីបទមនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិសាត់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ។

២-លើចោលការប្តឹងទាមទារជម្ងឺចិត្តរបស់ អ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] ចំនួន១០.០០០(ដប់ពាន់) ដុល្លារអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] ដោយខុសទៅនឹងគតិច្បាប់។

៣-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ ចំពោះមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិ ដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០១០កំបាំងមុខជនជាប់ចោទ និងអ្នកតំណាងដោយអាណត្តិដើមបណ្តឹងរដ្ឋប្បវេណី។



Scanned by CamScanner

104/5

បើកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ០៨ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ[redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ០៤"ផ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា: ពុំមានភស្តុតាងដោះបន្ទុកធនធ្ងន់អាចឱ្យជនត្រូវចោទរួចផុតពីបទចោទឡើយ។ គប្បីបដិសេធសាលក្រមលេខ០៤ "ផ" ចុះថ្ងៃទី០៩ ខែកុម្ភៈឆ្នាំ២០១០ ចោលជាអសារបង់ ដោយចោទប្រកាន់ជនត្រូវចោទ ដូចការចោទប្រកាន់របស់តំណាងអយ្យការ។

-បានឃើញសាលដីកាបៀបលេខ០៣ "ក្រVបស" ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ស៊ើបសួរបន្ថែមទូរ៖

-ពេលវេលាដែលជនរងគ្រោះត្រូវគេបាញ់សំលាប់

-ពេលវេលាផ្សេងៗទៀតរបស់ជនជាប់ចោទ និងសាក្សី ដែលបានឃើញហេតុការណ៍ និង សាក្សី ដែលនៅជាមួយជនជាប់ចោទ។

-សាកសួរលើឈ្មោះ[redacted]និងឈ្មោះ[redacted]នគរបាលនៃអធិការដ្ឋានក្រុងពោធិ៍សាត់ ពីពេលវេលា ដែលអ្នកទាំងពីរបានកសាងក្នុងកំណត់ហេតុ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៨៣"ក្រVបស"ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច:

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១០ របស់ឈ្មោះ [redacted] ជាតំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់។

២-បដិសេធសាលក្រមព្រហ្មទណ្ឌលេខ០៤"ផ" ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១០ របស់សាលាដំបូងខេត្តពោធិ៍សាត់ចោល។

៣-ផ្តន្ទាទោសជនជាប់ចោទឈ្មោះ[redacted]ភេទប្រុស អាយុ២៦ឆ្នាំ និងជនជាប់ចោទឈ្មោះ [redacted]ភេទប្រុស អាយុ៤៤ឆ្នាំ ដាក់ពន្ធនាគារម្នាក់ៗកំណត់១៧ឆ្នាំ ពីបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅភូមិសាលាគំរូ សង្កាត់ព្រៃញី ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៩។ តាមមាត្រា៣ នៃច្បាប់ស្តីពីការផ្តន្ទាទោសនៃបទឧក្រិដ្ឋ និងមាត្រា៣៥០ ចំណុច១, ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ[redacted]សំណងជម្ងឺចិត្តចំនួន២០.០០០.០០០រៀល (ម្ភៃលានរៀល) ទៅដើមបណ្តឹងឈ្មោះ[redacted]ការទាមទារលើសពីនេះ បដិសេធចោល។



Scanned by CamScanner

104/4

-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ[redacted]យកមកអនុវត្តទោសនៅពន្ធនាគារខេត្តពោធិ៍សាត់ តាមអំណាចសាលដីកានេះ។ តាមមាត្រា៤០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ ដោយសម្រេចសេចក្តី៖

-កំបាំងមុខដើមបណ្តឹងចំពោះមុខមេធាវី

-បើកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ២០៥,២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ[redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៨៣"ក្រVបស" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាខឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណាការពារ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ របស់លោ[redacted] មេធាវីការពារជនជាប់ចោទទាំងពីរនាក់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងឧត្តមអយ្យការតុលាការកំពូលថា:

-ទទួលបណ្តឹងសាទុក្ខលេខ២០៥ និង២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ឈ្មោះ[redacted]ជាត្រឹមត្រូវតាមទម្រង់ ប៉ុន្តែបដិសេធចោលដោយខ្វះអង្គ់ និងគតិច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៨៣ "ក្រVបស" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាខឧទ្ធរណ៍ ទុកជាបានការដដែល។

សូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យ និងសម្រេចតាមច្បាប់។

-បានស្តាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ[redacted] នាពេលសវនាការថា: មុនចាប់ខ្លួនខ្ញុំៗនៅផ្ទះលក់ចានឆ្នាំង ខ្ញុំមិនសុខចិត្តសាលដីកាសាលាខឧទ្ធរណ៍ចោទប្រកាន់ខ្ញុំ ព្រោះខ្ញុំមិនបានប្រព្រឹត្តទេ នៅថ្ងៃកើតហេតុ ពេលព្រឹកខ្ញុំទៅលក់ពីព្រឹកដល់យប់ទើបមកផ្ទះវិញ ពេលខ្ញុំភ្ញាក់ព្រើតដោយមិនបានដឹងអ្វីទាំងអស់។ ជនរងគ្រោះស្គាល់ គឺព្រោះគាត់ជាអ្នកស្រុកខ្ញុំៗពុំដែលមានទំនាស់ជាមួយគ្នាទេ នៅក្នុងភូមិខ្ញុំមានឈ្មោះ[redacted]ច្រើនហើយឈ្មោះ[redacted]ខ្ញុំក៏ច្រើនដែរ ដូច្នេះការដែលគេចោទប្រកាន់មកលើរូបខ្ញុំគឺជាការភ័ន្តច្រឡំ។

សំណូមពរ:ជួយដោះលែងខ្ញុំផង ព្រោះខ្ញុំមិនបានប្រព្រឹត្តទេ។

-បានស្តាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោ[redacted] នាពេលសវនាការថា: សព្វថ្ងៃខ្ញុំនៅផ្ទះធ្វើស្រែ ខ្ញុំជាមនុស្សស្អាតស្អំ បែរជាគេចោទខ្ញុំ ថាសម្លាប់មនុស្ស



Scanned by CamScanner

ទៅវិញ ក្នុងរឿងនេះខ្ញុំមិនបានប្រព្រឹត្តទេ។ ម៉ោង១១ថ្ងៃត្រង់ ខ្ញុំទៅផឹកកាហ្វេ គឺជួបមេប៉ុស្តិ៍ មេកង ឈ្មោះ[redacted]ពេលនោះខ្ញុំយកខឹសទៅធ្វើ អត់ជួបអ្នកធ្វើក៏ផឹកកាហ្វេ ខ្ញុំគ្មានទំនាស់អ្វីជាមួយជនរងគ្រោះទេ ផ្ទះខ្ញុំនៅឆ្ងាយពីផ្ទ[redacted]ប្រហែល៤០០ម ហើយពីផ្ទះខ្ញុំទៅកន្លែងកើតហេតុជិះម៉ូតូប្រហែល១ម៉ោង គេប្រាប់ខ្ញុំថាឈ្មោ[redacted]ត្រូវគេសម្លាប់ពេលនោះប្រហែលម៉ោង៤ទៅ៥ ខ្ញុំនៅផ្ទះចងគោ។

សំណូមពរ: រកយុត្តិធម៌ឱ្យខ្ញុំ ព្រោះគេចោទខ្ញុំដោយបំពាន។

-បានស្តាប់ប្រធានសួរសាវតាជាតិ និងចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]ពេលសវនាការថា: ប្តីខ្ញុំគាត់មានជម្ងឺជាប់ខ្លួន ប្តីខ្ញុំមិនមានទំនាស់គ្នាជាមួយនរណាទេ បើសិនជាមិនមែន០២នាក់ និងទេ គាត់មិនឆ្លើយដាក់ទេ ប្តីខ្ញុំគាត់ជាគ្រូបុរាណ គ្មានជំលួសជាមួយពីណាទេ ពេលគាត់ត្រូវរបួសពេលនោះ ខាងស្រុកសំពៅមាសសួរថា អ្នកណាបាញ់ គាត់ថាឈ្មោះ[redacted]ទាំងឈ្មោះប្រពន្ធទៀត។

សំណូមពរ: សូមតម្កល់សាលដីកាសាលាខេត្តរណ៍ ព្រោះក្នុងចិត្តនាងខ្ញុំគិតថា២នាក់និងជាអ្នកបាញ់ប្តីខ្ញុំ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធា[redacted]ការពារជនជាប់ចោទឈ្មោះ[redacted]នាពេលសវនាការថា: ឆ្លងតាមការសួរដេញដោល ខ្ញុំបាទសូមសន្និដ្ឋានអំពីអង្គហេតុ ខ្ញុំទទួលស្គាល់ថាជនរងគ្រោះឆ្លើយដាក់កូនក្តីខ្ញុំបាទ ប៉ុន្តែសម្រាប់កូនក្តីខ្ញុំវិញជាភាពអយុត្តិធម៌បំផុតម្រាប់កូនក្តីរបស់ខ្ញុំ ក្នុងការកសាងសំណុំរឿងដោយប៉ូលីសមានភាពស្រពេចស្រពិលពុំបានរកឃើញភស្តុតាងនានាពាក់ព័ន្ធនិងបទល្មើសនោះទេ នៅថ្ងៃកើតហេតុឈ្មោ[redacted]ឆ្លើយថា តាំងពីប្រហិតមខ្លួនជូនប្រពន្ធទៅលក់ចានឆ្នាំង លុះដល់ម៉ោង១០ត្រលប់មកដល់ផ្ទះវិញបោកខោអាវ ងូតទឹក ហូបបាយ បន្ទាប់មកចូលថ្វាយបង្គំព្រះក្នុងវិហារ ដោយមានសាក្សីដឹងពុច្រើននាក់។

ចំណែកឯឈ្មោះ [redacted] នៅថ្ងៃកើតហេតុខ្លួនយកខឹសទៅធ្វើពីម៉ោង១១ទៅម៉ោង១២ ថ្ងៃត្រង់គាត់ទៅផឹកកាហ្វេ ក្នុងទៀមកាហ្វេក្បែរសាលាឃុំអូរសណ្តាន់ ដោយមានសាក្សីជាច្រើននាក់ ពិសេសមេឃុំ មេប៉ុស្តិ៍ ទៅដល់ផ្ទះវិញរៀបចំខ្លួនចូលព្រះវិហារ។

សំណូមពរ: សូមច្រានចោលសាលដីកាព្រហ្មទណ្ឌលេខ៤១៥ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០ របស់សាលាខេត្តរណ៍ ទុកជាមិនបានការ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី[redacted]ការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីនាពេលសវនាការ ថា:ខ្ញុំបាទសូមទទួលស្គាល់ថាឈ្មោ[redacted]នច្រើន ប៉ុន្តែកូនក្តីខ្ញុំបាទឆ្លើយថាអ្នកដែលបាញ់សម្លាប់គេ គឺឈ្មោ[redacted]មទាំងបញ្ជាក់ពីឈ្មោះប្រពន្ធគេទៀត ដោយប្រពន្ធចុងកូនក្តីខ្ញុំបាទជាអ្នកស្តាប់ផ្ទាល់ឮថាឈ្មោះអ្នកទាំងពីរនេះជាអ្នកសម្លាប់។ ចំពោះសាលា



Scanned by CamScanner

ខុទ្ទរណ៍ដាក់ពន្ធនាគារកំណត់១៧ឆ្នាំ ហេតុអ្វីដាក់តែ[redacted]ក់ មិនដាក់ឈ្មោ[redacted]ង ដោយសាសនាអ៊ីស្លាមឪពុករបស់ [redacted] គាត់ជាគ្រូសូត្រប្រចាំភូមិ ព្រោះសាសនាអ៊ីស្លាមធំជាងច្បាប់ទៅទៀតដោយប្រជាជនគាំទ្រគាត់ ទើបគ្មាននរណាចេញមុខចាប់គាត់បាន។

សំណូមពរៈមេត្តាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន ប្តឹងសុំរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## <u>តុលាការកំពូល</u>

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ២០៥,២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទ ធ្វើឡើងក្នុងកំណត់ច្បាប់តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចផ្តន្ទាទោសឈ្មោ[redacted] ពីបទៈមនុស្សឃាដគិតទុកជាមុន ដោយផ្អែកតែលើភស្តុតាង ដែលនបានទទួលពីជនរងគ្រោះ តែមួយមុខនោះ តុលាការកំពូលពិនិត្យឃើញថា មិនទាន់គ្រប់គ្រាន់នៅឡើយ ពីព្រោះ៖

-តាមចម្លើយសាក្សីឈ្មោះ[redacted]ាប្រជាជននៅភូមិសាលាគំរូថា នៅពេលកើតហេតុខ្លួនឮសូរផ្ទុះ ស្មានថាបែកកង់ បន្ទាប់មកឃើញជនរងគ្រោះបណ្តើរម៉ូតូ មកដាក់មុខផ្ទះខ្លួន ហើយប្រាប់ខ្លួនថាម៉ូតូបែកកង់ខ្ទាតត្រូវរូបខ្លួនបណ្តាលឱ្យរបួស។

-តាមចម្លើយរបស់ឈ្មោ[redacted]ានៅពេលកើតហេតុ ខ្លួនឃើញម៉ូតូជរងគ្រោះជិះមុនរួចមានម៉ូតូ០១គ្រឿងទៀត ផ្ទុកមនុស្ស០២នាក់ ជិះតាមពីក្រោយម្នាក់ពាក់មួកសុវត្ថិភាព ម្នាក់ទៀតពាក់មួកក្រណាត់ លុះម៉ូតូចូលទៅកៀកគ្នាប្រហែល៣ម អ្នកជិះខាងក្រោមបានទាញកាំភ្លើងខ្លីចេញពីអាវបាញ់ជនរងគ្រោះ រួចជិះម៉ូតូទៅទិសខាងលិច។

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោ[redacted]ថាពេលចេញម៉ូតូមក បានឃើញឈ្មោះ[redacted]ងម្នាក់ទៀតឈ្មោះ[redacted]ជិះម៉ូតូតាមពីក្រោយខ្លួន មកដល់ជិតសាលាគំរូ បានបាញ់រូបខ្លួនត្រូវក្រោមឆ្អឹងជំនីរខាងឆ្វេង១គ្រាប់។

ដូច្នេះឃើញថា ចម្លើយរបស[redacted]សង្វាក់គ្នានឹងចម្លើយជនរងគ្រោះ ប៉ុន្តែហេតុអ្វីបានជាជនរងគ្រោះ ប្រា[redacted]តូបែកកង់ខ្ទាតមកត្រូវរូបខ្លួន បណ្តាលឱ្យរបួសទៅវិញ ព្រោះ[redacted]ាមនុស្សទីមួយ ដែលជនរងគ្រោះ បានប្រាប់ពីហេតុការនេះ ឬមួយក៏ក្រោយពេលរបួស

Scanned by CamScanner

ជនរងគ្រោះ មិនដឹងថាត្រូវគេបាញ់ ហើយស្មានថាកងបែកខ្ទាតថ្មមកត្រូវបណ្ដាលឱ្យរបួសទៅវិញ។ រីឯភិនភាគរបស់អ្នកទាំងពីរជាជនសង្ស័យ ក៏មិនបានដឹងដែរ។

-យល់ឃើញថា អាវុធ គឺកាំភ្លើងដែលត្រូវបានប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើសនេះ ក៏មិនទាន់បានស្រាវជ្រាវរកនៅឡើយ ដូច្នេះគប្បីសាលាឧទ្ធរណ៍ ធ្វើការស៊ើបអង្កេតបន្ថែម។

-យល់ឃើញថា នៅរយៈការអ្នកស្រី [redacted] ប្រពន្ធរបស់ឈ្មោះ [redacted] ជនរងគ្រោះ បានទាមទារសំណង និងជម្ងឺចិត្តជាប្រាក់ចំនួន១០.០០០$ ដែលចំណុចនេះ សាលាឧទ្ធរណ៍មិនទាន់បានពិចារណាទេ ផ្ទុយទៅវិញ សាលាឧទ្ធរណ៍បែរជាទទួលស្គាល់អ្នក [redacted] ម្នាក់ជាដើមបណ្ដឹងរដ្ឋប្បវេណី ដោយសម្រេចឱ្យសំណងជម្ងឺចិត្ត២០.០០០.០០០៛ ទៅវិញ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៨៣"ក្រVបស"ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ មិនត្រឹមត្រូវតាមគតិច្បាប់។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដី**

១-ទទួលបណ្ដឹងសាទុក្ខលេខ២០៥ និង២០៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១២ របស់ជនជាប់ចោទ។

២-បដិសេធសាលដីកាព្រហ្មទណ្ឌលេខ៨៣ "ក្រVបស" ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ របស់សាលាឧទ្ធរណ៍ទាំមូល។

៣-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ២១៥ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១២ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីចាត់ការតាមច្បាប់។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៣ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីច្បាប់ដើមត្រឹមត្រូវហើយ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៣

[redacted]

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ២០១៣

ប្រធានតុលាការកំពូល

[redacted]



Scanned by CamScanner